ព្រះរាជាណាចក្រកម្ពុជា-137
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ០៣
ចុះថ្ងៃទី០២ ០១ ២០០៣
សាលដីកា
លេខ : ៤៨
ចុះថ្ងៃទី០៣ ១២ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសម្ងាត់ នៅថ្ងៃទី០៣ខែ ធ្នូ ឆ្នាំ ២០០៣
ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រម
៣- លោក ជីវ កេង ចៅក្រម
៤- លោក ប្រាក់ គឹមសាន ចៅក្រម
៥- លោក យស់ សួខឿន ចៅក្រមរបាយការណ៍
លោក យ៉ាង ស្រ៊ុន ក្រឡាបញ្ជី
តំណាងមហាអយ្យការ
លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៤៥ ចុះថ្ងៃទី០៦ ០៨ ២០០២ របស់ សាលាឧទ្ធរណ៍និងសំណុំរឿងព្រហ្មទណ្ឌលេខ០៣ ចុះថ្ងៃទី០២ - ០១ - ២០០៣ របស់តុលាការកំពូល ។

ពីបទ : រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅខេត្តកំពង់ចាម កាលពីថ្ងៃទី១២ ខែ មិនា ឆ្នាំ ២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះយ៉ាង អាន "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣៤ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាមាឃចាស់ ឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ។ ទីលំនៅសព្វថ្ងៃ ភូមិតាមាឃចាស់ ឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ប្រពន្ធឈ្មោះលឹម ផល្លា បានកូន០៣នាក់ ឪពុកឈ្មោះនួន យ៉ាង ម្តាយឈ្មោះ ឡាងនាង ។

- មេធាវី លោក ជី បូរ៉ា

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជ សុខទាង "ម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ៤៤ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែចំការ ទីលំនៅសព្វថ្ងៃភូមិតាមាឃចាស់ ឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ។

- ជនរងគ្រោះឈ្មោះលាង ធារី "ជាអនីតិជន" ភេទ ស្រី អាយុ១៤ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ តាមាឃចាស់ ឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ។

- មេធាវី លោក ជុំ សោភា

....... .....

- តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៥ - ១០ - ២០០១ របស់ឈ្មោះជ សុខទាង ជាម្ដាយជនរងគ្រោះ បានប្ដឹងពីឈ្មោះយ៉ាង អាន ថា កាលពីថ្ងៃទី១២ .០៣ .២០០១ វេលាម៉ោង៧យប់ ខ្លួនបានប្រើកូនស្រីឈ្មោះណាង ធារី អាយុ១៤ ឆ្នាំ អោយទៅដងទឹកចំងាយ១០ម៉ែត្រពីផ្ទះ ពេលកំពុងដងទឹកស្រាប់តែឈ្មោះយ៉ាង អាន បានដើរលបពីក្រោយកូនស្រីខ្លួន ហើយចាប់កូនស្រីខ្លួនទៅអណ្ដូងទឹក ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតយកកាំបិតភ្ជង់កហើយគំរាមមិនអោយស្រែក ។ បន្ទាប់មកឈ្មោះនេះបានបណ្ដើរកូនខ្លួនទៅក្បែរដើមដូង ដើមទាម៉ាខាងកើតអណ្ដូងទឹក៥ម៉ែត្រ ហើយក៏រំលោភរហូតដល់សំរេច ។ ក្រោយរំលោភហើយឈ្មោះយ៉ាង អាន បានគំរាមកំហែងកូនស្រីខ្លួនថា បើប្រាប់ម៉ាក់ប៉ា គេនឹងសំលាប់ចោល ។ ពេលមកដល់ផ្ទះកូនស្រីខ្លួនបានប្រាប់ខ្លួនពីរឿងនេះ ប៉ុន្តែពេលនោះខ្លួនមិនបានប្ដឹងទៅសមត្ថកិច្ចទេ ដោយខ្លួនយល់ថាការទៅប្ដឹងនេះធ្វើអោយខ្មាស់គេ ។ លុះដល់ថ្ងៃទី២៤ - ៩ - ២០០១ ទើបមានលេចឮថា កូនខ្លួនខូចជាមួយឈ្មោះយ៉ាង អាន ពាក្យនេះគឺប្រពន្ធឈ្មោះយ៉ាង អាន ដើរនិយាយ ។ ខ្លួនសុំអោយផ្ដន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារជំងឺចិត្ត ៨ លានរៀល ។

- បានឃើញដីកាឃុំខ្លួនលេខ ២៦៨ព្រ ១ ចុះថ្ងៃទី១៥ .១១ .២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ចាមសំរេច បង្គាប់ឃុំខ្លួនឈ្មោះយ៉ាង អាន ភេទប្រុស អាយុ ៤៤ ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ កើតនៅនិងទីលំនៅសព្វថ្ងៃភូមិតាមាឃចាស់ ឃុំចុងដាច ស្រុកតំបែរ ខេត្តកំពង់ចាម ត្រូវចោទពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅខេត្តកំពង់ចាម កាលពីថ្ងៃទី១២ .០៣ .២០០១ បទល្មើសដែលមានចែងនិងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញដីកាលេខ ២២០ ចុះថ្ងៃទី២៧ .១១ .២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ចាម សំរេចអោយជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្ន ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១០៥ ចុះថ្ងៃទី២១ .០១ .២០០២ របស់ឈ្មោះជ សុខទាង ប្ដឹងតវ៉ាពីដីកាសំរេចអោយជនល្មើសនៅក្រៅឃុំ លេខ២២០ ចុះថ្ងៃទី២៧ .១១ .២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ចាម លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា : សុំអោយក្រុមប្រឹក្សាជំនុំជំរះបដិសេធដីកាសំរេចអោយជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្នលេខ ២២០ ព្រ.១ ចុះថ្ងៃទី២៧ .១១ .២០០០ ចោលជាអសារបង់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ០៥ "ច" ចុះថ្ងៃទី១៥ .០២ .២០០២ របស់ សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២១ - ០១ - ២០០២ របស់ឈ្មោះជ សុខទាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ - តំកល់ដីកាសំរេចអោយជនជាប់ចោទនៅក្រៅឃុំបណ្ដោះអាសន្នលេខ២២០ ព្រ.១ ចុះថ្ងៃទី២៧ .១១ .២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ចាម ទុកជាបានការដដែល ។

.....៣ ....

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងទាស់លេខ ០៤ ចុះថ្ងៃទី០១ .០៣ .២០០២ របស់ឈ្មោះជ សុខទាង តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ០៥ "ច" ចុះថ្ងៃទី១៥ .០២ .២០០២ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: តាមការអង្កេតដំបូង តុលាការរកមិនឃើញបទល្មើសទេ សូមតុលាការពិចារណាតាមច្បាប់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៤៥ "ច" ចុះថ្ងៃទី០៦ .៤ .២០០២ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី ០១ .០៣ .២០០២ របស់ឈ្មោះ ជ សុខទាង ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ - តំកល់សាលដីកាព្រហ្មទណ្ឌលេខ ០៥ "ច" ចុះថ្ងៃទី១៥ .០២ .២០០២ របស់ សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៦០ ចុះថ្ងៃទី០៦ .៤ .២០០២ របស់ឈ្មោះ ជ សុខទាង តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៤៥ ចុះថ្ងៃទី០៦ - ៤ - ២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១២ .០២ .២០០៣ របស់ឈ្មោះជ សុខទាង .

- បានឃើញលិខិតបង្គាប់ឱ្យឈ្មោះឈាង អាន ធ្វើសារណាតប តែឈ្មោះនេះមិនមាននៅលំនៅដ្ឋានទេ .

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះឈាង អាន ពីបទរំលោភសេពសន្ថវៈប្រព្រឹត្តកាលពីថ្ងៃទី១២ .៣ .២០០១ នៅភូមិតាមាឃចាស់ ឃុំចុងជាច ស្រុកតំបែរ ខេត្ត កំពង់ចាម បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

. សាលដីកាព្រហ្មទណ្ឌលេខ ៤៥ ចុះថ្ងៃទី០៦ .០៤ .២០០២ របស់សាលាឧទ្ធរណ៍ដែលសំរេចមកនេះមានការខុសឆ្គង ។

- បានស្តាប់សាវតាជាតិនិងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជ សុខទាង នាពេលសវនាការថា:

រឿងហេតុដែលនាងខ្ញុំបានដឹង ដោយសារប្រពន្ធរបស់ជនជាប់ចោទបានដើរឃោសនាប្រាប់អ្នកជិតខាងថា កូននាងខ្ញុំរួចខ្លួនជាមួយប្តីគាត់ ទើបនាងខ្ញុំសួរនាំកូនប្រាប់ថា:ពិតមែនៗ

ព្រោះឈ្មោះឈាង អាន ចាប់រំលោភពេលដែលនាងទៅដងទឹក ហើយគំរាមកំហែងគ្រប់មធ្យោបាយ បណ្តាលឱ្យកូននាងខ្ញុំតក់ស្លុតមិនហ៊ានប្រាប់គេឯងឱ្យដឹង ។ ពេលនោះហើយទើបនាងខ្ញុំប្តឹងដើម្បីរកយុត្តិធម៌ ដែលឈ្មោះនោះគេចខ្លួនបាត់ ហើយការដោះស្រាយចេះតែរួបបន្លាយយូរទៅៗ សូមមេត្តារកយុត្តិធម៌ អោយជនរងគ្រោះក្នុងគ្រួសាររបស់នាងខ្ញុំនិងផ្តន្ទាទោសជននោះតាមច្បាប់ ។

- បានស្តាប់មេធាវីលោក ជុំ សោភា ការពារឱ្យដើមបណ្តឹងលើកឡើងនាពេលសវនាការដែលមានសេចក្តីសន្និដ្ឋានរបស់ខ្លួនថា: នៅតុលាការខេត្ត កំពង់ចាមបានសំរេចឃុំខ្លួនជនល្មើស មានរយៈពេលតិចពេក ហើយត្រូវចៅក្រមស៊ើបអង្កេតឱ្យនៅក្រៅឃុំ ដោយយល់ថាពុំមានភស្តុតាង គ្រប់គ្រាន់និងមានអាសយដ្ឋានច្បាស់លាស់ ។ ដូច្នេះទាំងការអង្កេត ទាំងការដោះលែងជាហេតុ បង្កលក្ខណៈខុសពីនីតិវិធីនៃការស្រាវជ្រាវឱ្យល្អិតល្អន់ ម្យ៉ាងទៀតនាំឱ្យជនល្មើសជាអ្នកប្រព្រឹត្តនោះ គេចខ្លួនបាត់ ទើបកូនក្តីខ្ញុំប្តឹងឧទ្ធរណ៍ ដើម្បីរកយុត្តិធម៌ ត្រូវបានសាលាឧទ្ធរណ៍កាត់សេចក្តីតាមការយល់ឃើញរបស់តុលាការខេត្ត កំពង់ចាមដដែល នេះធ្វើឱ្យអស់ប្រសិទ្ធិភាពផ្លូវច្បាប់ ។ ជាពិសេសនារីរងគ្រោះត្រូវបានបាត់បង់កេរ្តិ៍ឈ្មោះកិត្តិយសសេចក្តីថ្លៃថ្នូរក្នុងសង្គម សូមមេត្តាបដិសេធសាលដីកាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ ដើម្បីស្វែងរកចាប់ជនល្មើសធ្វើការអង្កេតជាថ្មីម្តងទៀតទៅតាមច្បាប់ ។

- បានស្តាប់មេធាវីលោក ជី បូរ៉ា ការពារឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួននាពេលសវនាការថា:បញ្ហារឿងចោទប្រកាន់នោះ ឃើញថា គ្រាន់តែមានពាក្យបណ្តឹងប៉ុណ្ណោះ ពុំមានលក្ខណៈណាមួយថា កូនក្តីរបស់ខ្ញុំចាប់រំលោភកូនរបស់ដើមបណ្តឹងឡើយ ព្រោះគ្មានភស្តុតាងនិងសាក្សីណាមួយបង្ហាញច្បាស់លាស់នៅឡើយ បើពិនិត្យទៅលើទីកន្លែងកើតហេតុ ជនរងគ្រោះទៅដងទឹកអណ្តូងក្បែរផ្ទះប្រជាជន ហើយចាប់ទាញដៃពីអណ្តូងទឹកមកខាងក្រោយផ្ទះមានចម្ងាយប្រហែល១០ម៉ែត្រ បើនារីនោះស្រែកច្បាស់អ្នកនៅទីនោះគេឮនឹងឃើញ ប៉ុន្តែរឿងនេះ គ្រាន់តែចោទតាមពាក្យបណ្តឹងដាក់បន្ទុកលើកូនក្តីខ្ញុំប៉ុណ្ណោះ សូមតម្កល់សាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ទុកជាបានការវិញ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់របស់តំណាងមហាអយ្យការនាពេលសវនាការថា: សូម ក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យនិងសំរេច ព្រោះជនរងគ្រោះជាអនីតិជន ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងសេចក្តីសន្និដ្ឋានការពារ របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទ ។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

តុ លា កា រ កំ ពូ ល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៦០ ចុះថ្ងៃទី៦ .៨ ២០០២ របស់ឈ្មោះដ សុខទាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

....៥ ....

- យល់ឃើញថាការដែលសាលាឧទ្ធរណ៍សំរេចអនុញ្ញាតិអោយជនជាប់ចោទ ឈ្មោះ យោង អាន ភេទប្រុសអាយុ ៣៤ ឆ្នាំ មានទីលំនៅភូមិតាមាយចាស់ ឃុំចុងផាច ស្រុកតំបែរ ខេត្តកំពង់ចាម នៅក្រៅឃុំបណ្ដោះអាសន្ន ដោយអាងហេតុថាជនជាប់ចោទមានទីលំនៅច្បាស់លាស់ មានមុខរបរពិតប្រាកដ មានគ្រួសារច្បាស់លាស់និងមានអ្នកធានាត្រឹមត្រូវនោះ គឺជាការភន្តច្រឡំ ពីព្រោះថាបច្ចុប្បន្នជនជាប់ចោទព្រមទាំងគ្រួសារនិងអ្នកធានាពុំដឹងថារស់នៅទីណាទេ ។ម្យ៉ាងទៀតរឿងនេះជារឿងឧក្រិដ្ឋ ដែលតាមមាត្រា១៤នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ការឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្នរង់ចាំតុលាការជំនុំជំរះ[illegible]ចប់ដល់អង្គសេចក្ដីគឺជាការចាំបាច់ ។

- យល់ឃើញថា ជនជាប់ចោទពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ចុះថ្ងៃទី៦ខែកញ្ញា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខ

ជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសារទុក្ខលេខ ៦០ ចុះថ្ងៃទី៦ - ៩ - ២០០២ របស់ឈ្មោះ ជ សុខទាង ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ៤៩ចុះថ្ងៃទី៦ -៩ - ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - សំរេចអោយចាប់និងឃុំខ្លួនជាបណ្ដោះអាសន្នជនជាប់ចោទ យោង អាន ភេទប្រុស ជាតិខ្មែរ អាយុ ៣៤ ឆ្នាំ រង់ចាំតុលាការសំរេចដល់អង្គសេចក្ដី ។

៤ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ០៣ ចុះថ្ងៃទី០២ - ០១ - ២០០៣ របស់តុលាការកំពូលទៅតុលាការខេត្តកំពង់ចាម ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្ដី ។

៥ - សាលដីកានេះជំនុំជំរះជាសម្ងាត់និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៣ ។/.